# សេចក្តីថ្លែងការណ៍របស់ហេង_ពៅ (ត)

បកប្រែក្រៅផ្លូវការដោយ លី-ឌៀប
ថ្ងៃទី១៧ សីហា ២០០៦

★ <u>ជួយគណបក្សប្រឆាំង</u> ៖

នៅឆ្នាំ២០០០, ខ្ញុំបានជួបទំនាក់ទំនងជាមួយពួកបក្សប្រឆាំង ។ ខ្ញុំធ្វើនេះពីព្រោះខ្ញុំជឿថារដ្ឋាភិបាលហ៊ុន-សែនពុករលួយ ហើយការសង្ឃឹមស្រុកខ្មែរ គឺត្រូវតែឆ្លងកាត់តាមរយៈពួកគណបក្សប្រឆាំងប៉ុណ្ណោះ ។ ហ៊ុន-សែនគាត់ប្រឡាក់ឈាមច្រើនណាស់នៅក្នុងដៃ ដោយបានសម្លាប់មនុស្សជាច្រើន ។ ខ្ញុំចង់ឃើញការផ្លាស់ប្តូរនៅក្នុងរដ្ឋាភិបាលខ្មែរ ដើម្បីនាំមកនូវលទ្ធិប្រជាធិបតេយ្យនិងយុត្តិធម៌ដល់ខ្មែរ ។ ពេលខ្ញុំបានឮហុក-ឡុងឌីនិងហ៊ុន-សែនឃុបឃិតគ្នារកសម្លាប់ពួកគេ ខ្ញុំបានទៅប្រាប់ពួកមេដឹកនាំខាងក្រុមប្រឆាំងឲ្យបានដឹងមុនជាសម្ងាត់ តាមរយៈទាក់ទងផ្ទាល់ជាមួយមនុស្សជិតស្និទ្ធ ហើយនិងបានព្រមានពួកគេទុកជាមុន ។

ខ្ញុំបានស្នើពួកគេឲ្យរួមកម្លាំងគ្នា ដើម្បីមានឱកាសល្អឈ្នះឆ្នោតនាឆ្នាំ២០០៨ខាងមុខ ។ ខ្ញុំក៏បានបង្ហាញផងដែរនូវភស្តុតាងខ្លះៗ ពីការពុករលួយរបស់ហ៊ុន-សែនទៅថ្នាក់ដឹកនាំក្រុមប្រឆាំងបានឃើញ ដើម្បីពួកគេបើកបង្ហាញទៅសាធារណៈ ។ កាលពីចុងខែមិថុនា/កក្កដា ឆ្នាំ២០០៦, ហ៊ុន-សែនបានរកឃើញថា ខ្ញុំបាននិយាយជាមួយពួកប្រឆាំង និងផ្តល់គំនិតដល់ពួកគេជាដើម ។ គាត់មិនសប្បាយចិត្តនឹងខ្ញុំទេ ។ គាត់ចោទខ្ញុំថា ខ្ញុំមិនស្មោះត្រង់ជាមួយគណបក្សប្រជាជន ។

នៅថ្ងៃទី២៣កក្កដា, ខ្ញុំបានចាកចេញពីស្រុកខ្មែរទៅកាន់ប្រទេសម៉ាឡេស៊ី ដើម្បីឲ្យគេឆែកពិនិត្យមើលជើងខាងឆ្វេងរបស់ខ្ញុំ និងរួចហើយទៅកាន់ប្រទេសសឹង្ហបូរីដើម្បីមើលកូន និងដើម្បីឲ្យពួកម៉ាកជួយកាត់វែនតា ។ មុនពេលខ្ញុំចេញដំណើរ ខ្ញុំបានសុំការអនុញ្ញាតទៅបរទេស ហើយគេក៏បានផ្តល់នូវការអនុញ្ញាតឲ្យខ្ញុំ ។ នៅថ្ងៃទី២៨កក្កដា, ខ្ញុំបានឮពីស្រុកខ្មែរនិងពីមិត្តភក្តិមកថា ខ្ញុំពុំអាចវិលត្រឡប់វិញបានឡើយ ពីព្រោះហ៊ុន-សែនខឹងនឹងខ្ញុំខ្លាំងណាស់ ហើយចោទប្រកាន់ខ្ញុំថាជាជនក្បត់គណបក្សប្រជាជន ។ ពួកគេកំពុងបំភ្លៃការចោទប្រកាន់ប្រឆាំងមកលើខ្ញុំ ។

★ <u>និយាយចេញ</u> ៖

ជាមួយអ្វីទាំងអស់ដែលខ្ញុំបានរកឃើញអំពីហ៊ុន-សែននិងហុក-ឡុងឌី, ខ្ញុំមានការអស់សង្ឃឹមក្នុងចិត្ត ។ ខ្ញុំប្រៀបដូចទូកកំពុងវង្វេងក្នុងសមុទ្រដ៏ធំធេង ។ ខ្ញុំមាន

គោលជំហរនិងឧត្តមគតិរបស់ខ្ញុំ ប៉ុន្តែនៅក្នុងពិភពពុករលួយ គ្មានច្រកចេញបានទេ ។ ដើម្បីរស់ ខ្ញុំត្រូវតែបិទភ្នែករបស់ខ្ញុំចំពោះអំពើឧក្រិដ្ឋជាច្រើន ដែលខ្ញុំបានឃើញ ។ គឺដូចការស្លាប់ ស្ថិតនៅក្នុងខ្លួនខ្ញុំអញ្ចឹង ។ នៅក្នុងដំណាក់កាលបី ចន្លោះចាប់ពីឆ្នាំ១៩៩៩, ២០០០ និងឆ្នាំ២០០១, ខ្ញុំបានសំរេចចិត្តនិយាយជាមួយក្រុមអង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) នៅកម្ពុជា ។ ខ្ញុំបាននិយាយជាមួយអ្នកស្រីពុង-ឈីវហ្កេក, នាយកអង្គការលីកាដូនៅកម្ពុជា, អ្នកស្រី អ៊ីវ៉ា នៅអង្គការ Global Witness នៅភ្នំពេញ, លោក Henrick អតិតតំណាង UNHCR នៅភ្នំពេញ, លោក Christopher Peschoux, UNHCR នៅក្រុងហ្សឺណែវ, លោក Paul Grove ក្រសួងស៊ើបការណ៍អាមេរិកាំងប្រឆាំងគ្រឿងញៀន និងចុងក្រោយគេជាមួយ ណាលី នៅអង្គការលីកាដូប្រទេសកម្ពុជា ។

★ <u>ការសម្លាប់ចៅក្រមសុក-សេដ្ឋាមុនី</u> ៖

ខ្ញុំបានអាននៅក្នុងកាសែតបរទេសនិយាយថា ខ្ញុំបានត្រូវហ៊ុន-សែនចោទប្រកាន់ពាក់ព័ន្ធក្នុងការសម្លាប់ចៅក្រមសុក-សេដ្ឋាមុនី ។ នេះគឺជាការប្រឌិតរបស់ហ៊ុនសែនសុទ្ធសាធ ដើម្បីបំផុសបំផុលការប្រឆាំងមកលើរូបខ្ញុំ ។

នៅឆ្នាំ២០០៣, ចៅក្រមបានត្រូវសម្លាប់ដោយក្រុមភេរវជន ដែលមានឈ្មោះថា CFF ។ ប៉េអ៊ឹមនៅភ្នំពេញបានចាប់ខ្លួនជនសង្ស័យ៣នាក់ ដែលពាក់ព័ន្ធនៅក្នុងការសម្លាប់ ។ ការចាប់ខ្លួនធ្វើឡើងដោយស័ក្តិប្រាំស៊ឹម-ហុង, ជាមេប៉េអ៊ឹមក្រុមស៊ើបអង្កេត ។ ខ្ញុំគ្មានអ្វីពាក់ព័ន្ធនឹងការចាប់ខ្លួននេះទេ ពីព្រោះជាកិច្ចខាងប៉េអ៊ឹម ។

ជនដែលគេចាប់ខ្លួនមាន ជន-ចិត្រា និងមូល-ម៉េត, តែខ្ញុំមិនចាំឈ្មោះអ្នកម្នាក់ទៀតនោះទេ ។

ខ្ញុំមានការគោរពចំពោះចៅក្រម ហើយខ្ញុំខ្លួនឯងក៏ស្គាល់គាត់យ៉ាងច្បាស់ពិតប្រាកដណាស់ ។ គ្មានផ្លូវអ្វី ដែលខ្ញុំត្រូវរៀបចំសម្លាប់គាត់នោះឡើយ ។

ខ្ញុំជឿថា នេះគ្រាន់តែជាការបំភ្លៃផ្តោលទោសមកលើខ្ញុំដើម្បីចាប់ខ្លួនប៉ុណ្ណោះ ។ ខ្ញុំដឹងរឿងច្រើន ដូច្នេះខ្ញុំត្រូវគេចោមពីគ្រប់ទិសទី ។

★ <u>ការចាប់បានអាភៀន៣៦គីឡូក្រាម</u> ៖

នៅឆ្នាំ២០០១, ខ្ញុំបានទទួលពត៌មានពីជនលាក់មុខម្នាក់ និយាយថាវរៈសេនីយ៍ទោងឿ-សម្បត្តិ ជាមនុស្សរបស់ឧត្តមសេនីយ៍សៅ-សុខា (ផ្កាយបី) និងឧត្តមសេនីយ៍ដុំ-ហាក់ (ផ្កាយ២) ពាក់ព័ន្ធក្នុងរឿងជួញអាភៀន ។ ក្រោយបន្ទាប់ពីការស៊ើបអង្កេត ខ្ញុំបានទៅផ្ទះគាត់នៅសង្កាត់ទួលគោកក្នុងក្រុងភ្នំពេញ ហើយចាប់បានអាភៀនចំនួន៣៦គីឡូក្រាម ។ វរៈសេនីយ៍ទោបានត្រូវចាប់ខ្លួននៅនឹងកន្លែង តែដុំ-ហាក់ដែលស្ថិតនៅទីនោះ បានគេចខ្លួនពីកន្លែងកើតហេតុ ។ យើងមានបំណងតាមដេញចាប់គាត់, តែហ៊ុន-សែនបានបញ្ជាប់យើង ដោយបញ្ជាឈប់ចាប់ដុំ-ហាក់ និងមិនឲ្យធ្វើការស៊ើបអង្កេតពីដុំ-ហាក់អ្វីទាំងអស់ ។ ខ្ញុំត្រូវតែឈប់ដេញតាម និងធ្វើការ

ស៊ើបអង្កេត ។ ជំនួសធ្វើការផ្តន្ទាទោសគាត់ ជាការគួរឲ្យភ្ញាក់ផ្អើល ហ៊ុន-សែនបាន ដំឡើងឋានន្តរស័ក្តិគាត់ផ្កាយ៣ តែក្នុងប្រហែលមួយខែក្រោយមកប៉ុណ្ណោះ ។ ង៉ឿ-សម្បត្តិ បានត្រូវគេសម្លាប់នៅក្នុងគុក ។ ហ៊ុន-សែនបាននិយាយប្រាប់ខ្ញុំថា មិនត្រូវខ្លាំងដៃពេក អំពីរឿងជួញដូរគ្រឿងញៀននោះទេ ។

ក្រោយពីនេះមិនយូរប៉ុន្មាន គេមានការងារមួយរៀបចំឡើងដោយហុក-ឡុងឌី សំរាប់ឧត្តមសេនីយ៍ទាំងអស់នោះ ។ សៅ-សុខានៅទីនោះ ហើយខ្លួនខ្ញុំក៏គេហៅឲ្យទៅដែរ ។ សៅ-សុខាកោតសរសើរខ្ញុំយ៉ាងច្រើននៅការងារនោះ និងចង់ឲ្យខ្ញុំជិតស្និទ្ធជាមួយគាត់ ។ គាត់និយាយនឹងខ្ញុំថា បើយើងរួមដៃគ្នា យើងអាចធ្វើអ្វីបានទាំងអស់នៅស្រុកខ្មែរ ។ រួចគាត់និយាយថា អ្វីតែមួយគត់នោះគឺជំហររបស់ខ្ញុំអំពីជំនួញគ្រឿងញៀន ។ គាត់បានសុំខ្ញុំឲ្យឈប់ស៊ើបអង្កេតអំពើរត់ពន្ធគ្រឿងញៀន ដោយនិយាយថាគ្រឿងញៀនពុំបង្កបញ្ហាអ្វីដល់កម្ពុជាទេ ។ ខ្ញុំឆ្លើយចំពោះមុខគាត់វិញថា ខ្ញុំមិនយល់ស្របតាមទេ ។ គាត់ស្រាប់តែខឹងហើយនិយាយមកខ្ញុំថា បើខ្ញុំនៅតែបន្តធ្វើការស៊ើបអង្កេត នោះគាត់នឹងប្រើដាវរបស់គាត់សម្លាប់ខ្ញុំ ។

អ្នកដទៃឃើញហេតុការណ៍យ៉ាងដូច្នេះ ក៏នាំគ្នាមកឃាត់យើងឲ្យស្ងប់ ។

★ <u>សំណូមពរកំណែទំរង់តុលាការនិងយុត្តិធម៌</u> ៖

នៅដើមឆ្នាំ២០០៥, ខ្ញុំបានសំណូមពរទៅនាយករដ្ឋមន្ត្រីហ៊ុន-សែនរបស់ខ្ញុំ ធ្វើកំណែទំរង់ប្រព័ន្ធតុលាការនិងយុត្តិធម៌ ដែលពុករលួយ ។ ចៅក្រមភាគច្រើនទូទាំងប្រទេសមិនសប្បាយចិត្តនឹងខ្ញុំទេ ជាពិសេសព្រះរាជអាជ្ញា អ៊ុក-សាវុធ ដែលគេស្គាល់ថាជាមេពុករលួយ ។ នាយករដ្ឋមន្ត្រីហ៊ុន-សែនគាំទ្រខ្ញុំ ហើយគាត់បានប្រកាសជាសាធារណៈ ឲ្យធ្វើកំណែទម្រង់ប្រព័ន្ធតុលាការ ។ ប្រជាពលរដ្ឋស្វាគមន៍ទង្វើនេះ ហើយនាំគ្នាអបអរសាទរ ដោយនាំគ្នាសរសេរជាចំរៀង ដែលមានរំឭកពីឈ្មោះខ្ញុំនៅក្នុងនោះផង ។ ខ្ញុំបានប្រាប់ទៅពួកគេថា ធ្វើអញ្ចឹងនាយករដ្ឋមន្ត្រី គាត់មិនសប្បាយចិត្តនឹងឃើញឈ្មោះខ្ញុំត្រូវលើកដម្កើងច្រើនពេកទេ ។ អ៊ុក-សាវុធ មិនសប្បាយចិត្តនឹងខ្ញុំ ពេលគាត់បានឃើញកំណែទំរង់ មានកម្លាំងបញ្ចប់នូវអ្វីដែលគាត់ធ្វើបានក្រោមប្រព័ន្ធបច្ចុប្បន្ន ។

★ <u>ហេតុការណ៍ថ្មីៗរបស់ខ្ញុំ--ទាក់ទងផ្ទាល់នឹងមុខតំណែងរបស់ខ្ញុំនៅក្នុងរដ្ឋាភិបាល និងការជំនះយ៉ាងចំហរបស់ខ្ញុំ ប្រឆាំងហុក-ឡុងឌី និងនាយករដ្ឋមន្ត្រី</u> ៖

នៅឆ្នាំ២០០៥, ហុក-ឡុងឌីបានបញ្ជាឲ្យខ្ញុំសម្លាប់រដ្ឋលេខាធិការ នុត-សាអាន ពីព្រោះលោកនុត-សាអាន មានទំនាស់ជាមួយហុក-ឡុងឌី លើរឿងដីធ្លីមួយកន្លែងរបស់ប៉ូលិស ។ ហុក-ឡុងឌីខឹងយ៉ាងខ្លាំងជាមួយគាត់ ហើយបានបញ្ជាឲ្យរៀបចំសម្លាប់គាត់ ។ ខ្ញុំប្រកែក ពីព្រោះខ្ញុំគោរពគាត់យ៉ាងច្រើន និងមិនចង់ឃើញគាត់ត្រូវគេសម្លាប់ ។ ខ្ញុំក៏បានរករឿងដើម្បីដោះខ្លួន ។ ខ្ញុំបានពន្យល់ទៅហុក-ឡុងឌីថា នុតសាអាន មានអង្គរក្សច្រើនណាស់ ពុំអាចធ្វើអ្វីបានឡើយ ។

នៅខែធ្នូឆ្នាំ២០០៥, ហុក-ឡុងឌីមានទំនាស់ជាមួយខ្ញុំ ពីព្រោះគាត់ចង់ឲ្យខ្ញុំកាត់ផ្តាច់សោផ្ទះមេធាវីខ្មែរ-អាមេរិកាំងម្នាក់ឈ្មោះ David Chinava និងឲ្យធ្វើការឆែកឆេរ ។ មូលហេតុនៃការឆែកឆេរគឺថា មេធាវីត្រូវគេនិយាយថា ថ្ងៃមួយស្រវឹងហើយបានបើកឡានចូលទៅក្នុងសួនសាធារណៈរបស់ហ៊ុន-សែន ។ គាត់បានគេចខ្លួនចេញពីទីកន្លែងកើតហេតុ ហើយសម្ងំនៅស្ងៀម ។ ប្រហែល១០ថ្ងៃក្រោយមក ប៉ូលិសចាប់ផ្តើមធ្វើការស៊ើបអង្កេត ហើយបានរកឃើញឡានស្ថិតនៅផ្ទះដែលគាត់ចុះចោល ។ ផ្ទះចាក់សោ គឺហេតុដូច្នេះហើយ បានជាគាត់បញ្ជាឲ្យខ្ញុំទៅកាត់សោ ដើម្បីចូលទៅខាងក្នុង ។ ខ្ញុំមិនស្តាប់បញ្ជារបស់គាត់ទេ ហើយប្រាប់ហុក-ឡុងឌីថា ការធ្វើដូច្នេះគឺខុសច្បាប់ ។ ហុក-ឡុងឌីរកាំចិត្តនឹងខ្ញុំ ដែលមិនព្រមគោរពតាមបញ្ជារបស់គាត់ ។ គាត់ស្រែកគំហកសួរខ្ញុំថា តើហេតុអ្វីបានជាប៉ូលិសប្រុស-ប៉ូលិសស្រីក្នុងស្រុកលែងគោរពគាត់យ៉ាងដូច្នេះ ។ ខ្ញុំគឺជាមនុស្សតែម្នាក់គាត់ ដែលហ៊ានមិនគោរពតាមគាត់ ។ គាត់និយាយថា គាត់ពុំអាចលើកលែងឲ្យជនណា ដែលមិនគោ-រពគាត់បានសោះឡើយ ។

នៅដើមឆ្នាំ២០០៥, កូនប្រុសហុក-ឡុងឌី ឈ្មោះហុក-ឡុងដាវ ដែលគេស្គាល់ថាជា ឌី-វិជ្ជា បានលះលែងប្រពន្ធរបស់ខ្លួនឈ្មោះ ហ៊ុន-ចន្ទា ត្រូវជាក្មួយស្រីរបស់ហ៊ុន-សែន ។

ឧប្បត្តិហេតុនៅខាងលើ ដែលខ្ញុំបានប្រកែកមិនគោរពតាមគាត់ បានធ្វើឲ្យគាត់ប្រឆាំងខ្ញុំយ៉ាងជូរចត់ ។ គាត់ចង់គំនុំនឹងខ្ញុំ ។ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៥, គាត់បានហៅពួកស្នងការប៉ូលិស, អភិបាលខេត្ត និងមន្ត្រីជាន់ខ្ពស់នៃសង្កាត់ទាំង៧ ទៅប្រជុំគ្នាឯផ្ទះចៅហ្វាយក្រុងភ្នំពេញ ។ មនុស្សប្រហែល៤០០នាក់បានទៅបង្ហាញមុខ ។ ខ្ញុំក៏ជាអ្នកទៅចូលរួមម្នាក់ដែរ ។ ហុក-ឡុងឌីគាត់បានបើកបង្ហាញអំពីការមិនពេញចិត្តរបស់គាត់យ៉ាងចំហ ហើយបានប្រកាសថា គាត់នឹងធ្វើនូវអ្វីដែលអាចធ្វើទៅបាន ដើម្បីដកហូតឋានន្តរស័ក្តិខ្ញុំក្នុងរវាង៣ខែទៀត ។ ខ្ញុំនិយាយថា គាត់ត្រូវតែសំរេចនូវគោលដៅនេះ តែបើគាត់មិនសំរេចវិញ គាត់ត្រូវតែដកផ្កាយ២របស់គាត់ចេញ ។ ចំពោះខ្ញុំ, គាត់ប្រកាសសង្គ្រាមជាសាធារណៈប្រឆាំងខ្ញុំ ។ គាត់និយាយថា គាត់គឺជាមេក្រុមម៉ាហ្វីយ៉ានៅស្រុកខ្មែរ ហើយគ្មាននរណាអាចយកឈ្នះលើគាត់បានឡើ-យ សូម្បីតែទីប្រឹក្សារបស់នាយករដ្ឋមន្ត្រីក៏ដោយ ។ ខ្ញុំបានទទួលនូវអាត់សម្លេងដែលប៉ូលិសជាមិត្តភក្តិផ្សេងទៀតនៅក្នុងពេលប្រជុំបានថតទុក ។ កាសែតខ្មែរក៏បានចុះផ្សាយអំពីរឿងនេះផងដែរ ។

ភ្លាមក្រោយប្រជុំ, ខ្ញុំបានទៅរកនាយករដ្ឋមន្ត្រីឲ្យជួយធ្វើអន្តរាគមន៍ ។ នាយករដ្ឋមន្ត្រីនិយាយប្រាប់ខ្ញុំថា កុំបារម្ភអ្វី ហើយថាគាត់គ្មានផ្លូវទុកឲ្យហុក-ឡុងឌីដកចេញពីតំណែងបានឡើយ ។ គាត់និយាយថា ខ្លួនគាត់ផ្ទាល់ក៏មានបញ្ហាជាមួយហុក-ឡុងឌីដែរ ។

★ <u>ការសម្លាប់ជនជាតិសឹង្ហបូរីម្នាក់</u> ៖

ខ្លួនខ្ញុំក៏បានត្រូវគេចោទប្រកាន់ ក្នុងការសម្លាប់ទៅលើជនជាតិសឹង្ហបូរីម្នាក់ផងដែរ ។ វាជាការមិនទំនងទាល់តែសោះ ហើយតើហេតុអ្វីបានជាខ្ញុំត្រូវធ្វើដូច្នេះ ?

ខ្ញុំប្រាកដណាស់ គ្មានការពាក់ព័ន្ធនៅក្នុងការសម្លាប់ជនជាតិសឹង្ហបូរីឈ្មោះ ស៊ុម-ពីងសាយ នេះទេ ។ ខ្ញុំស្គាល់គាត់ច្បាស់ណាស់ និងបានចាត់ទុកគាត់ជាមិត្តរបស់ខ្ញុំផងដែរ ។ ស៊ុមត្រូវបានគេបាញ់សម្លាប់នៅដើមឆ្នាំ២០០៤ ។ រហូតមកដល់ថ្ងៃនេះ គ្មាននរណាត្រូវបានចាប់ខ្លួនពីរឿងសម្លាប់នេះសោះ ។

ស៊ុម ជាអ្នកជំនួញជនជាតិសឹង្ហបូរីម្នាក់ ។ គាត់ជាមួយជនជាតិសឹង្ហបូរីម្នាក់ទៀតឈ្មោះលោក កុក បានចូលហ៊ុនគ្នារកស៊ីជាមួយអ្នកជំនួញខ្មែរឈ្មោះប៊ុនហ៊ី ។ គឺប្រហែល១០ឆ្នាំមកហើយ ។ ការចូលហ៊ុនគ្នា គឺដើម្បីសង់ផ្ទះសំណាក់មួយមាន៣០០បន្ទប់ ។ គេកើតមានបញ្ហាបន្តបន្ទាប់គ្នា ពាក់ព័ន្ធនឹងសំណង់នោះ ។ អ្នកចូលហ៊ុនទាំងបីនាក់ក្រោយមកក៏លែងទុកចិត្តគ្នាទៅវិញទៅមក ។ ដោយសារសភាពការណ៍នៃគំរោងនេះ, ឧបនាយករដ្ឋមន្ត្រី សៅ-កាហេង (<u>កកន</u> ៖ ប្រហែលចង់សំដៅទៅលើស- ខេង) បានបញ្ជាឲ្យខ្ញុំធ្វើអន្តរាគមន៍ និងដើម្បីស្វែងរកដំណោះស្រាយបញ្ហា ។ គឺហេតុដូច្នេះឯងហើយ ទើបខ្ញុំបានជួបលោកស៊ុម និងលោកកុក ។

ខ្ញុំនៅចាំ ក្រោយពេលខ្ញុំបានប្រមូលហៅអ្នកទាំងបីមកជួបជុំគ្នាបន្តិច, លោកកុកបានប្តឹងខ្ញុំអំពីលោកស៊ុមបោកប្រាស់លុយកាក់គាត់ ។ លោកស៊ុមមិននៅក្នុងប្រជុំទេ ។ លោកកុកបាននិយាយផងដែរថា គាត់ខ្លាចលោកស៊ុម ពីព្រោះលោកស៊ុម ប្រហែលឲ្យគេត្រូវរៀបចំសម្លាប់គាត់ ហើយគាត់ក៏មិនចង់វិលត្រឡប់ទៅស្រុកខ្មែរវិញដែរ ។ ការប្រជុំនេះធ្វើនៅសឹង្ហបូរី ។ មុនប្រជុំ, ខ្ញុំបានជួបជាមួយលោកកុកជាច្រើនដង ហើយនិងក៏បានទទួលសំបុត្រពីលោកកុកនៅឯស្រុកខ្មែរផងដែរ ។ លោកស៊ុមបានខាតបង់វិនិយោគទុនរបស់គាត់យ៉ាងច្រើននៅក្នុងគំរោងការ ហើយចង់ដកខ្លួនចេញដោយការលក់អាគារ ។ គាត់បានស្នើលក់អាគារចែកហ៊ុនគ្នា ។ ការព្រមព្រៀងបានធ្វើក្នុងអនុស្សារណៈព្រមព្រៀង (MOU) មួយ ហើយមានប្រថាប់ត្រារដ្ឋាភិបាលផង ។ ពីព្រោះការមិនទុកចិត្តគ្នាទៅវិញទៅមក, ខ្ញុំក៏ធ្វើជាភ្នាក់ងារលក់ និងឃោសនាផ្សព្វផ្សាយដំណឹង ដោយដាក់លេខទូរស័ព្ទរបស់ខ្ញុំជាចំណុចទាក់ទងក្នុងការលក់ ។ ការតថ្លៃទិញក៏បានទទួលមក តែយើងពុំអាចលក់បាន ពីព្រោះតម្លៃលក់ចេះតែដំឡើងជានិច្ច ។ នេះមួយផ្នែក ពីព្រោះក្រោយពេលលោកស៊ុមត្រូវគេសម្លាប់ ប្រពន្ធរបស់គាត់ឡើងកាន់កាប់ ហើយនិងទាក់ទងផ្ទាល់ជាមួយភាគី២ផ្សេងទៀត ។ ដូច្នេះស្ថានភាពពុំផ្តល់ឲ្យខ្ញុំលក់អាគារបានឡើយ ។ ការរកាំរកូសប្រទាំងប្រទើសគ្នាបានបន្តរហូតមកទល់ពាក់កណ្តាលឆ្នាំ២០០៤ ខ្ញុំក៏ទម្លាក់ចោលទៅ ។ ខ្ញុំអស់ចិត្តនឹងបញ្ហារបស់ពួកគេ ហើយក្រៅអំពីនេះ ខ្ញុំក៏មានបញ្ហាផ្ទាល់ខ្លួនយ៉ាងច្រើននាពេលនោះផងដែរ ។៚